ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

៣៣*៧៧

លេខៈ ៤៨១

ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៥

ក្នុងនាមប្រជារាស្ត្រខ្មែរ

<u>សាលដីកា</u>

តុលាការកំពូល

លេខៈ ២១០

ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៦

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ឌិត មុន្នី** ជាប្រធាន

២-លោក រៀល មួន ជាចៅក្រម

៣-លោក ស៊ិន អ៊ិម ជាចៅក្រមរបាយការណ៍

៤-លោក ប៉ែន សារឿន ជាចៅក្រម

៥-លោក ម៉ុង មុន្នីចរិយា ជាចៅក្រម

ក្រឡាបញ្ជី

លោក **ម៉ៅ សុខធន្ណ**

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ១០៨"ឃ"ចុះថ្ងៃទី២៧ខែតុលា ឆ្នាំ២០០៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤១៤ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **គុំ ចាន់ស៊ិត** (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅផ្ទះលេខ១៨ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

ចុងចម្លើយឈ្មោះ **គួច គិមជូ** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅផ្ទះលេខ ២៥ ផ្លូវ៣៦៧ សង្កាត់ច្បារអំពៅ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ។

- ចុងចំលើយឈ្មោះ សឿង ស៊ីវខេង ,និង ឈ្មោះចៅ ហ៊ីក.

<u>**កម្មវត្ថុចណ្តឹង**</u> : ប្តឹងសុំមោឃភាពកិច្ចសន្យាលក់-ទិញ .

បានឃើញបណ្តឹងសាទុក្ខលេខ៤២៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ របស់ឈ្មោះគួច គិមជូ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១០៨"ឃ" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៨៨១ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៧-០១-២០០២ របស់ដើមចោទឈ្មោះកុំ បានយ៉ិន បានប្តឹងសុំមោឃភាពកិច្ចសន្យាលក់ទិញផ្ទះ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី០៤-១០-២០០១ ដោយហេតុថា : កាលពីថ្ងៃទី០៤-១០-២០០១ ខ្លួនបានខ្ចីប្រាក់ឈ្មោះចៅ ហ៊្វិក ចំនួន ៩០០០ដុល្លាអាមេរិក ដោយឱ្យការប្រាក់ក្នុង១ខែ ៣៦០ដុល្លាអាមេរិក ។ នៅពេលខ្ចីប្រាក់នេះ ឈ្មោះចៅហ៊្វិក បានប្រើល្បិចលួងលោមឱ្យខ្លួនធ្វើកិច្ចសន្យាលក់ផ្ទះ និង លិខិតផ្ទេរសិទ្ធិកាន់កាប់ផ្ទះដើម្បីប្រាក់បំណុលរបស់គាត់ ។ នៅខែ ១២ និង ខែ០១ ឆ្នាំ២០០២ នេះ ខ្លួនពុំបានបង់ការប្រាក់ឱ្យគាត់តាមកាលកំណត់ ស្រាប់តែឈ្មោះចៅ ហ៊្វិក នេះបានយកកំលាំងទាយានមកបណ្តេញខ្លួនឱ្យរុះរើឥវ៉ាន់ចុះចេញពីផ្ទះរបស់ខ្លួន ។ ខ្លួនសុំរំលាយកិច្ចសន្យាលក់ទិញ និងលិខិតផ្ទេរសិទ្ធិ និងសុំឱ្យឈ្មោះចៅហ៊្វិក ដឹកកំលាំងដែលមកដេកនៅផ្ទះរបស់ខ្លួនចេញ ។

បានឃើញដីកាសំរេចតាមពាក្យសុំលេខ ០២"ឱ"ចុះថ្ងៃទី០៥ ខែមិនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៤-១២-២០០២ របស់ឈ្មោះកុំ បានយ៉ិន ភេទស្រី អាយុ៥៣ឆ្នាំ មានទីលំនៅក្រុមទី៩ ភូមិជ្រោយបាសាក់ សង្កាត់ព្រែកប្រា ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ប្តឹងសុំហាមឃាត់ឈ្មោះចៅហ៊្វិក មិនឱ្យលក់ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិ ឬធ្វើអំណោយទានដល់អ្នកដទៃជាបណ្តោះអាសន្ននូវផ្ទះលេខ ៥៨ ក្រុមទី៩ ផ្លូវលេខ ៣៦៩ ភូមិជ្រោយបាសាក់ សង្កាត់ព្រែកប្រា ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ហាមឃាត់ឈ្មោះចៅ ហ៊្វិក ភេទប្រុស មិនឱ្យលក់-ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិ ឬធ្វើអំណោយទានទៅអ្នកដទៃជាបណ្តោះអាសន្ន នូវផ្ទះលេខ ៥៨ ផ្លូវលេខ ៣៦៩ ក្រុមទី៩ ភូមិជ្រោយបាសាក់ សង្កាត់ព្រែកប្រា ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ រង់ចាំតុលាការសំរេចដល់រឿងអង្គសេចក្តី ។

៣-បង្គាប់ឱ្យឈ្មោះកុំ បានយ៉ិន បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីងចំនួន ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ សរុប ២០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ដែលដើមចោទបានបង់ទុករួចជាស្រេច ។

៤-ដីកានេះ មានអានុភាពអនុវត្តភ្លាមៗ ទោះបីជាមានបណ្តឹងទាស់ក៏ដោយ ។

៥-បើគូភាគីណា មិនសុខចិត្តនឹងដីកានេះ មានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃដែលបានទទួលដីកាសំរេចនេះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៥៥"ឱ" ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះគុំ បានយ៉ិន ចុះថ្ងៃទី១៧-១-២០០២ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយខុសនឹងគតិច្បាប់ ។

២-ទទួលស្គាល់កិច្ចសន្យាលក់ផ្ទះចុះថ្ងៃទី៤-១០-២០០១ ជាច្បាប់របស់គូភាគី ផ្អែកតាមមាត្រា៣ នៃច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

៣-ប្រគល់ផ្ទះនិងដីស្ថិតក្នុងក្រុមទី៩ ភូមិជ្រោយបាសាក់ មណ្ឌល២ សង្កាត់ព្រែកប្រា ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ មានបណ្ណស្នាក់នៅលេខ ១៩១៦ ក្បាល២.២ ទំព័រ៦៣ ចុះថ្ងៃទី១៨-៦-១៩៩៩ ឱ្យឈ្មោះចៅ ហ្វិក ឈ្មោះគួច គឹមជូ និងឈ្មោះសៀង ស៊ីវខេង គ្រប់គ្រងជាកម្មសិទ្ធិតាមស្មារតីនៃច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

៤-បង្គាប់ឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តីពន្ធចុះបញ្ជីក្តី និងពន្ធហ្វិនចំនួន១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ និងរង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥០០០៛ សរុប៧០០០៛ ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើហួសឧទ្ធរណ៍បង្គាប់ឱ្យដើមចោទបង់ប្រាក់១%នៃប្រាក់ចំនួន៩០០០ដុល្លាអាមេរិក ។ ប្រាក់នេះសំរាប់បង់ចូលថវិការដ្ឋ៨០% និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៥-សាលក្រមនេះជំនុំជំរះនិង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចុងចំលើយ សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៦"ឧ" ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះគុំ បានយ៉ិន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៩៥"ឧ"ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១០៨"យ" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះគុំ បានយ៉ិន ចុះថ្ងៃទី២៩-០១-២០០៤ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមលេខ៩៥"ឧ" ចុះថ្ងៃទី៣១-១២-២០០៣ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-មោឃៈកិច្ចសន្យាលក់ផ្ទះនិងលិខិតផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី៤-១០-២០០១។

៤-បង្គាប់ឱ្យឈ្មោះគួច គឹមជូ ,ចៅហ្វិក,សៀង ស៊ីខេង ប្រគល់ផ្ទះ និងដីស្ថិតនៅក្នុងក្រុមទី៩ ភូមិជ្រោយបាសាក់ មណ្ឌល២ ឃុំព្រែកប្រា ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញឱ្យទៅឈ្មោះគុំ បានយ៉ិន ។

៥-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០រៀលពន្ធចុះបញ្ជីក្ដី និង ពន្ធភ្លើង ២៩៥០រ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៥៥០រ ចំណាយលើការប្រគល់ដីកាកោះ៥០០០រ និងលើអាជ្ញាធរតុលាការ ៥.០០០រ ។

៦-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី២១-១០-២០០៥ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧-១០-២០០៥ ចំពោះមុខគូភាគី ។ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៤២៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ របស់ឈ្មោះគួច គីមជូ ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១០៨"យ" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ខែធ្នូ ឆ្នាំ២០០៥ របស់ឈ្មោះចៅហ្វ៊ីក.គួចគីមជូ. និង ឈ្មោះសឿង ស៊ីវខេង ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលាឧទ្ធរណ៍សំរេចសេចក្ដីមកនេះត្រឹមត្រូវហើយ សុំតំកល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្ដាប់ចំលើយរបស់ឈ្មោះគួច គីមជូ នាពេលសវនាការថា : បានជាខ្ញុំប្ដឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ មកពីសាលាឧទ្ធរណ៍កាត់មិនយុត្តិធម៌ ។ ប្រាក់នេះជាថ្លៃទិញផ្ទះ ៣៦០ដុល្លា ជាថ្លៃឈ្នួលផ្ទះ គាត់មិនដែលឱ្យថ្លៃឈ្នួលផ្ទះទេ ។ រឿងនេះជារឿងទិញផ្ទះ មិនមែនចងការទេ ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយរបស់ចុងចំលើយ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**ខុសាចារកំខូល**

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៤២៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ របស់អ្នកស្រីគួច គីមជូ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ថ្វីត្បិតតែគូភាគីបានធ្វើកិច្ចសន្យាលក់-ទិញ និងផ្ទេរសិទ្ធិលើដី និងផ្ទះ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០១ ជាលាយលក្ខណ៍អក្សរ និងមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានលើកិច្ចសន្យាទាំងនោះក៏ពិតមែន ប៉ុន្តែក៏មានភស្តុតាងជាលិខិតចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១ ដែលមានខ្លឹមសារថា : សុំសងប្រាក់ដើមចំនួន ៨០០០ដុល្លា និងការប្រាក់ ហើយនៅពេលដាក់ពាក្យបណ្ដឹង

តបចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០២ ភាគីចុងចំលើយបានទាមទារប្រាក់ជំពាក់ចំនួន៩០០០ដុល្លា មិនមែនទាមទារសិទ្ធិគ្រប់គ្រងដី និងផ្ទះនោះទេ ។

- យល់ឃើញថា ក្នុងរឿងនេះ កិច្ចសន្យារបស់គូភាគីមានអត្ថន័យមិនច្បាស់លាស់ឡើយ ព្រោះកិច្ចសន្យាខ្លះមានខ្លឹមសារថា ជាការលក់-ទិញ និងផ្ទេរសិទ្ធិលើដី និងផ្ទះ ហើយក៏មានកិច្ចសន្យាខ្លះមានខ្លឹមសារថា ជាការខ្ចីប្រាក់ ដូចនេះតាមមាត្រា២៣ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ត្រូវបានបកស្រាយជាប្រយោជន៍នៃភាគីកូនបំណុល ហើយម្យ៉ាងទៀត កិច្ចសន្យារវាងគូភាគី ធ្វើឡើងក្នុងសភាពដែលភាគីម្ខាងឆ្លៀតទាញយកប្រយោជន៍ពីភាគីម្ខាងទៀត ហើយមានភាពខុសគ្នា មិនសមស្របរវាងតារាកាលិក និងតំលៃតបដែលដើមចោទមានសិទ្ធិសុំមោឃភាពតាមមាត្រា ១១.១២.នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចទុកជាមោឃៈកិច្ចសន្យាលក់-ទិញ និងផ្ទេរសិទ្ធិលើដី និងផ្ទះចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០១ ហើយមិនបានសំរេចឱ្យដើមចោទបង្វិលប្រាក់ចំនួន៩០០០ដុល្លាអាមេរិក ទៅចុងចំលើយ ដោយសំអាងថា ចុងចំលើយមិនទាមទារប្រាក់នោះ ជាការខុសឆ្គងនឹងមាត្រា២១ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាហើយ ។

- យល់ឃើញថា តុលាការកំពូលបានជូនដំណឹងឱ្យដើមចោទតាមនីតិវិធីរួចហើយ តែដើមចោទពុំបានចូលរួមនាសវនាការនេះទេ ដូចនេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១០៨"យ"ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលបានសំរេចមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ ឯគតិច្បាប់ត្រូវខ្លះខុសខ្លះ គប្បីបង្វិលឱ្យជំនុំជំរះឡើងវិញនូវចំណុចខុសនោះ ។

**ហេតុដូចនេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខចុងចំលើយ**

**កំបាំងមុខដើមចោទ ប៉ុន្តែចាត់ជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ ៤២៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ របស់អ្នកស្រីតួច គឹមជូ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែគតិច្បាប់ត្រូវខ្លះ ខុសខ្លះ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ១០៨"យ" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៤៨១ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះលើចំណុចប្រាក់ដើម ។

៤-រំបអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រីគួចគីមជូ បានបង់នៅតុលាការកំពូលចំនួន១៩០០០រគឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៦។